

## យុវវ័យ

## ការចងចាំព្រះអម្ចាស់ជារៀងរាល់ថ្ងៃ




មិត្តភក្តិ ការងារផ្ទះ កិច្ចការសាលា ទូរទស្សន៍ — មានអ្វីៗជាច្រើនទៀតដែលទាក់ទាញចំណាប់អារម្មណ៍របស់យើង ។ ប៉ុន្តែរៀងរាល់សប្តាហ៍ យើងសន្យានឹងព្រះវរបិតាសួគ៌ « ថា [ យើង ] ចងចាំ [ ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ] ជានិច្ច » ( គ. និង ស. ២០:៧៩ ) ។

ប្រធាន អាវរិង មានប្រសាសន៍ថា យើងអាច « ធ្វើការជ្រើសរើសរៀងរាល់ថ្ងៃ » នូវកិច្ចការនានាដែលជួយយើងឲ្យចងចាំដល់ព្រះអង្គសង្គ្រោះ ។ ចូរគិតពីការដាក់គោលដៅមួយក្នុងខែនេះ ដើម្បីចងចាំព្រះអង្គសង្គ្រោះកាន់តែខ្លាំងឡើងជារៀងរាល់ថ្ងៃ ។ អ្នកអាចធ្វើកាលវិភាគមួយ ហើយតាំងចិត្តធ្វើកិច្ចការមួយរៀងរាល់ថ្ងៃ ។ ប្រធាន អាវរិង រៀបរាប់ពីកិច្ចការនានាដូចជា ការអានព្រះគម្ពីរ ការអធិស្ឋានដោយសេចក្តីជំនឿ និងការបម្រើព្រះអង្គសង្គ្រោះ និងអ្នកដទៃ ។ មានកិច្ចការនានាដូចជា ការសរសេរកំណត់ហេតុ ការចូលរួមការប្រជុំនានានៅសាសនាចក្រ ការស្តាប់សន្និសីទទូទៅ ការទៅព្រះវិហារបរិសុទ្ធ ការច្រៀងទំនុកតម្កើង — មានកិច្ចការផ្សេងៗទៀត ! ពេលយើងចងចាំព្រះអង្គសង្គ្រោះជារៀងរាល់ថ្ងៃ ប្រធាន អាវរិង សន្យាថា « ពរជ័យ . . . នឹងកើតមានឡើងបន្តិចម្តងៗ និងទៀងទាត់ . . . [ ហើយ ] នឹងជះឥទ្ធិពលដល់យើងឲ្យប្រែក្លាយជាសិស្សដ៏ពិតរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។

## កុមារ

### សេចក្តីស្រឡាញ់ដ៏ច្រើនលើសលប់

នៅពេលយើងអានព្រះគម្ពីរ ឬអធិស្ឋាន នោះយើងអាចទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់ដ៏ខ្លាំង ដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវមានចំពោះយើង ។ សូមផាត់ពណ៌នៅក្នុងរូបបេះដូងរាល់ពេលដែលអ្នកអធិស្ឋាន ឬអានព្រះគម្ពីរ ។ តើអ្នកអាចធ្វើអ្វីខ្លះទៀតដើម្បីទទួលអារម្មណ៍ខិតជិតព្រះវរបិតាសួគ៌ និងព្រះយេស៊ូវ ?

